# ស្វែងយល់ពីរបៀបដែល SUN Bucks អាចជួយគ្រួសាររបស់អ្នកបាន!

SUN Bucks គឺជាកម្មវិធីអត្ថប្រយោជន៍ទិញគ្រឿងទេស ដើម្បីជួយគ្រួសារនានាអាចទិញអាហារក្នុងអំឡុងពេលវិស្សមកាលរដូវក្តៅនៅពេលសាលារៀនបិទទ្វារ។ គ្រួសារនានានឹងទទួលបានទឹកប្រាក់ $120 សម្រាប់កុមារក្នុងវ័យសិក្សាម្នាក់ដែលមានសិទ្ធិចូលរួម។ កុមារដែលទទួលបានអត្ថប្រយោជន៍ទាំងនេះនៅតែអាចចូលរួមក្នុងកម្មវិធីផ្តល់អាហាររដូវក្តៅផ្សេងទៀតបាន។

## តើកូនរបស់ខ្ញុំមានលកណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ SUN Bucks ដែរឬទេ?

កូនរបស់អ្នកមានលកណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ SUN Bucks ប្រសិនបើបំពេញតាមលកខណ្ឌណាមួយក្នុងចំណោមលកខណ្ឌដូចខាងក្រោម៖

- គ្រួសាររបស់អ្នកកំពុងចូលរួមក្នុងកម្មវិធីជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារខ្វះខាត (Temporary Assistance for Needy Families) ឬ SNAP (Supplemental Nutrition Assistance Program, កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម) រួចហើយ ហើយកូនរបស់អ្នកមានអាយុចន្លោះពី 8-18 ឆ្នាំ។
- កូនរបស់អ្នកចូលរៀននៅសាលាដែលមានផ្តល់ជូនកម្មវិធីអាហារថ្ងៃត្រង់តាមសាលារៀនថ្នាក់ជាតិ (National School Lunch Program) ឬកម្មវិធីអាហារពេលព្រឹកនៅសាលា (School Breakfast Program) ហើយចំណូលគ្រួសាររបស់អ្នកបំពេញតាមតម្រូវការដើម្បីទទួលបានអាហារដោយឥតគិតថ្លៃ ឬបញ្ចុះតម្លៃនៅសាលា។ អ្នកអាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍អប់រំ និងសិទ្ធិទទួលបានអាហារូបត្ថម្ភសម្រាប់កុមារ (Child Nutrition Eligibility and Education Benefit) នៅសាលារបស់កូនអ្នក ដើម្បីបញ្ជាក់ថាតើកូនរបស់អ្នកមានលកខណ្ឌសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានអាហារឥតគិតថ្លៃ ឬបញ្ចុះតម្លៃដែរឬទេ។

## តើគ្រួសារនានាទទួលបានអត្ថប្រយោជន៍ SUN Bucks តាមរបៀបណា?

គ្រួសារដែលមានលកណៈសម្បត្តិគ្រប់គ្រាន់ភាគច្រើនមិនចាំបាច់ដាក់ពាក្យស្នើសុំនោះទេ ពីព្រោះពួកគេត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិក្នុងកម្មវិធី SUN Bucks ហើយ។ គ្រួសារទាំងនេះនឹងទទួលបានកាត SUN Bucks តាមរយៈសំបុត្រប្រៃសណីយ៍ក្នុងខែមិថុនា។
ប្រសិនបើអ្នកមិនត្រូវបានចុះឈ្មោះដោយស្វ័យប្រវត្តិទេ អ្នកនៅតែអាចដាក់ពាក្យស្នើសុំក្នុងអំឡុងរដូវក្តៅនេះបាន។

## តើខ្ញុំត្រូវដាក់ពាក្យស្នើសុំ SUN Bucks ដោយរបៀបណា?

សូមចូលទៅកាន់ sunbucks.dshs.wa.gov ដើម្បីដាក់ពាក្យស្នើសុំតាមអ៊ីនធឺណិតជាភាសាអង់គ្លេស។ អ្នកក៏អាចស្កេនកូដ QR ដើម្បីស្វែងរកពាក្យស្នើសុំ SUN Bucks ដែលបានបកប្រែជាភាសាផ្សេងៗ និងបោះពុម្ពវាផងដែរ។

សូមផ្ញើពាក្យស្នើសុំដែលបានបំពេញរួចទៅកាន់៖
DSHS Customer Service Center
P.O. Box 11669
Tacoma, WA 98411-6699

នៅពេលដាក់ពាក្យ អ្នកនឹងត្រូវស្នើសុំឱ្យផ្តល់ឈ្មោះកូន សាលារៀន ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងចំណូលគ្រួសាររបស់អ្នក។ អ្នកមិនចាំបាច់ផ្តល់ឯកសារ ឬព័ត៌មានផ្សេងទៀតនៅពេលអ្នកដាក់ពាក្យនោះទេ។ អ្នកប្រហែលជាត្រូវផ្តល់ព័ត៌មានបន្ថែមទៀត មុនពេលអាចផ្តល់ជូនអត្ថប្រយោជន៍បាន។

**តើមានសំណួរអំពីអត្ថប្រយោជន៍ SUN Bucks របស់អ្នកឬទេ? តើត្រូវការធ្វើបច្ចុប្បន្នភាពអាសយដ្ឋានរបស់អ្នកមែនទេ?**

សូមទូរសព្ទទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនង SUN Bucks តាមលេខ 833-543-3230 ឬ TTY 800-833-6348

Washington Office of Superintendent of
PUBLIC INSTRUCTION